ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ : ១៨ អយក. សណ.ន

# សេចក្ដីណែនាំ
# ស្ដីពី
# ការអនុវត្តវិធានការការពារសុខភាព និងបង្ការជំងឺផ្សេងៗដែលបណ្ដាលមកពីអាកាសធាតុក្ដៅខ្លាំង នៅតាមគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន

ក្នុងគោលបំណងជំរុញការអនុវត្តវិធានការការពារសុខភាព និងបង្ការជំងឺមួយចំនួននៅរដូវក្ដៅ ដោយបន្ថែមលើខ្លឹមសារនៃសេចក្ដីប្រកាសព័ត៌មាន របស់ក្រសួងសុខាភិបាល ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការបង្ការជំងឺបណ្ដាលមកពីអាកាសធាតុក្ដៅខ្លាំងដូចជា ជំងឺបេះដូង ជំងឺសួត និងជំងឺផ្សេងៗមាន ជំងឺរាក ជំងឺកង្វះចំណីអាហារ ហើយក៏អាចមានបញ្ហាសុខភាពផ្លូវចិត្ត និងរលាកស្បែកឡើងក្រហមជាដើម ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដល់គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនទាំងអស់ ត្រូវណែនាំបន្តដល់បុគ្គលិកអប់រំ និងអ្នកសិក្សា ឱ្យអនុវត្តនូវវិធានការដូចខាងក្រោម ៖

- ត្រូវប្រកាន់ខ្ជាប់នូវក្បួនអនាម័យល្អ ហូបស្អាត ផឹកស្អាត រស់នៅស្អាត
- ត្រូវស្លៀកសម្លៀកបំពាក់សមរម្យ រលុង
- ត្រូវពាក់មួកការពារ ឬប្រើប្រាស់ឆ័ត្រពេលធ្វើដំណើរ
- ត្រូវឧស្សាហ៍ផឹកទឹកឱ្យបានច្រើន (ទឹកដាំពុះ ទឹកសុទ្ធ ទឹកចម្រោះ ទឹកស្អាត) កុំចាំដល់ពេកស្រេកទឹក ពិសេសត្រូវតាមដានទឹកនោម ដោយមិនត្រូវបណ្ដោយឱ្យទឹកនោមឡើងពណ៌លឿង ឬក្រហមនោះទេ
- ត្រូវណែនាំសិស្សឱ្យយកទឹកពីផ្ទះ សម្រាប់ផឹក (ទឹកដាំពុះ ទឹកសុទ្ធ ទឹកចម្រោះ ទឹកស្អាត) និងទឹកសម្រាប់ប្រើប្រាស់ ចំពោះគ្រឹះស្ថានសិក្សាដែលគ្មានទឹក
- ត្រូវចៀសវាងផឹកកាហ្វេ និងគ្រឿងស្រវឹង
- ត្រូវឧស្សាហ៍បរិភោគបន្លែ និងផ្លែឈើឱ្យបានញឹកញាប់



អាសយដ្ឋានលេខ៨០ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ៤២៧ ៣៩៦ / ២១៧ ២៥៣ / ៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣)២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ: www.moeys.gov.kh

- ត្រូវបើកទ្វារ បង្អួចនៃបន្ទប់រៀនឱ្យបានស្រឡះល្អ
- ត្រូវណែនាំអ្នកសិក្សាឱ្យលេងក្នុងម្លប់ ឬនៅក្នុងបន្ទប់រៀននៅពេលចេញលេង
- ត្រូវបន្តដាំ និងថែរក្សាដើមឈើដែលមានស្រាប់នៅក្នុងបរិវេណគ្រឹះស្ថាន ដើម្បីយកម្លប់ និងកាត់បន្ថយកំដៅ
- បើមានលទ្ធភាព គួរបាញ់ទឹកដាក់ទីធ្លាតាមគ្រឹះស្ថានសិក្សា ឬដំបូលអគារសិក្សា ដើម្បីបន្ថយកំដៅ
- ត្រូវអនុវត្តឱ្យបានខ្ជាប់ខ្ជួន នូវសេចក្តីណែនាំ ស្តីពីការលើកកម្ពស់សុវត្ថិភាពចំណីអាហារ និងអាហារប្រកបដោយសុខភាពនៅតាមគ្រឹះស្ថានសិក្សា សាធារណៈ និងឯកជន តាមលិខិតលេខ ១៨ អយក សណន ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១៣
- ត្រូវមានទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធក្នុងការផ្គត់ផ្គង់ទឹកសម្រាប់ផឹក និងទឹកសម្រាប់ប្រើប្រាស់នៅតាមគ្រឹះស្ថានសិក្សា
- ត្រូវអប់រំផ្សព្វផ្សាយវិធានការនេះ ដល់បុគ្គលិកអប់រំ និងអ្នកសិក្សាទាំងអស់ជាបន្ទាន់
- ក្នុងករណីមានជំងឺរាតត្បាត ឬហានិភ័យសុខភាព ដែលបណ្តាលមកពីការឡើងកំដៅ សូមធ្វើការរាយការណ៍ តាមរយៈសមត្ថកិច្ចពាក់ព័ន្ធនៅតាមមូលដ្ឋានរបស់ខ្លួន ដើម្បីដោះស្រាយជាបន្ទាន់។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡា គ្រប់ រាជធានី ខេត្ត ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡា ក្រុង ស្រុក ខណ្ឌ និងគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន ដើម្បីអនុវត្តឱ្យបានលទ្ធផលល្អប្រសើរ និងមានប្រសិទ្ធភាពខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមេសា ឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិត ហង់ ជួន ណារ៉ុន**

**<u>ចម្លងជូន</u>**

- គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធ *"ដើម្បីជូនជ្រាប និងសហការ"*
- សាលារាជធានី ខេត្ត *"ដើម្បីជូនជ្រាប"*
- មន្ទីរ អយក រាជធានី ខេត្ត *"ដើម្បីមុខការ"*
- អង្គភាពពាក់ព័ន្ធក្រោមឱវាទ *"ដើម្បីមុខការ"*
- គ្រប់គ្រឹះស្ថានសិក្សា *"ដើម្បីអនុវត្ត"*
- កាលប្បវត្តិ
- ឯកសារ នសស